# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 891

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ពង្រឹងការអភិរក្សជីវៈចម្រុះ និងព្រៃស្តុកកាបូននៃប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជា តាមរយៈកិច្ចសហការគ្រប់គ្រង និងអនុវត្តបង្ហាញពីការអភិរក្សទំបន់ទេសភាពខាងកើតទន្លេមេគង្គ (CAMPAS)

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 30/05/18 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/21 |
| ៣. ចំណាយគម្រោងសរុប | $165,317 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងបរិស្ថាន |
| RESPONSIBLE UNIT | Department of Community Livelihood, General Directorate of Local Community |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានជីវភាពសហគមន៍ នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន |
| ៥. ស្ថានភាពគម្រោង | គម្រោងដែលបានលុបចោល |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ជំនួយឥតសំណង |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- លើកកម្ពស់ជីវភាពរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រសង្គមមួយដែលបានប្តេជ្ញចិត្តក្នុងការការពារបរិស្ថាន
- ធានានិរន្តភាពបរិស្ថាន និងពង្រឹងភាពជាដៃគូអភិវឌ្ឍន៍

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

មណ្ឌលគិរី,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

• ពង្រឹងកិច្ចសម្របសម្រួលសហការរវាងមន្ត្រីរាជរដ្ឋាភិបាល(ថ្នាក់ជាតិ និងថ្នាក់ខេត្ត) និងសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដើម្បីលើកកម្ពស់ការងារគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិ
• កំណត់ព្រំប្រទល់ សិទ្ធកាន់កាប់ដីធ្លី សិទ្ធប្រើប្រាស់ដីធ្លី និងព្រមព្រៀងទៅលើតំបន់គ្រប់គ្រងជា យុទ្ធសាស្រ្តរបស់ សហគមន៍ (សកម្មភាពនៅសហគមន៍ ឬហៅថាកិច្ចព្រមព្រៀងអភិរក្ស)
• រៀបចំបង្កើតនិង លើកកម្ពស់ការគ្រប់គ្រងធនធម្មជាតិនៅថ្នាក់សហគមន៍ និងកិច្ចសហប្រតិបត្តិការជាមួយគម្រោងកម្មវិធីរ៉េតបូកថ្នាក់ជាតិ។
• លើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ តាមរយៈកម្មវិធីលើកកម្ពស់ជីវភាពដោយនិរន្តរភាព
• រៀបចំស្តារជម្រកសត្វព្រៃតាមរយៈការដំណុះព្រៃឈើ និងលើកកម្ពស់ការអនុវត្តកសិឧស្សាហកម្ម
• បង្កើនធនធាន និងសន្តិសុខស្បៀង សម្រាប់សហគមន៍នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ
• រៀបចំផែនការ និងចុះកិច្ចព្រមព្រៀងជាមួយអ្នកពាក់ព័ន្ធស្តីពីការអនុវត្តការដាំស្តារ និងធ្វើសុរ៉ុឡកម្មព្រៃឈើ

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងនេះគឺជាការបែងចែកការទទួលខុសត្រូវតាមផ្នែករវាងអគ្គនាយកដ្ឋានចំណុះក្រសួងបរិស្ថាន និងអង្គការដៃគូដែលផ្តោតលើការងារអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ដើម្បីអនុវត្តផែនការការងារ និងគោលបំណងរួមអំពី "ការពង្រឹងអភិរក្សជីវចម្រុះ និងព្រៃស្តុកកាបូននៃប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជា តាមរយៈកិច្ចសហការគ្រប់គ្រង និងអនុវត្តបង្ហាញពីការអភិរក្សទំបន់ទេសភាពខាងកើតទន្លេមេគង្គ" សម្រាប់គម្រោងរយៈពេល៥ឆ្នាំ។ គោលដៅចម្បងរបស់គម្រោងនេះគឺការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ ប្រទេសកម្ពុជា និងធានាឱ្យបាននូវកាបូនព្រៃឈើតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការអន្តរវិស័យ ការផ្សារភ្ជាប់គ្នា នៃទំនាក់ទំនងតំបន់ទេសភាព និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ការកើនឡើងនៃចំនួនសហគមន៍តំបន់ការពារធម្មជាតិ គឺជាផ្នែកមួយឆ្លើយតបទៅនឹងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព តាមរយៈការចូលរួមរបស់ប្រជាសហគមន៍មូលដ្ឋានដែលរស់និងនៅក្បែរក្នុងតំបន់ការពារធម្មជាតិ ហើយទទួលបានផលប្រយោជន៍ពីការចូលរួមរបស់ពួកគេទាំងក្នុងតម្រូវការជាក់ស្តែង និងតម្រូវការយុទ្ធសាស្ត្រ។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៨ កម្ពុជាមានតំបន់ការពារធម្មជាតិជាង៤៨កន្លែង និងរបៀងអភិរក្សជីវៈចម្រុះដែលគ្របដណ្តប់លើផ្ទៃដីជាង ៧,៥លានហិកតា ស្មើនឹង៤១% នៃផ្ទៃដីប្រទេសស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដែលមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានជាសេនាធិការដឹកនាំគ្រប់គ្រង និងអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះដែរ សហគមន៍តំបន់ការពារធម្មជាតិមានការកើនឡើងសរុបចំនួន ១៥១សហគមន៍ ត្រូវបានបង្កើតឡើងគ្របដណ្តប់ភូមិចំនួន ២៦៨ភូមិ ឃុំចំនួន ៨៤ឃុំ ដែលមានសមាជិកគ្រួសារចំនួន៣៧១៨៦គ្រួសារ ចូលរួមក្នុងការគ្រប់គ្រងការពារ និងប្រើប្រាស់ធនធានធម្មជាតិ លើផ្ទៃដីសរុបចំនួន ២៥៥,០៧៦ហិកតា នៅក្នុងនិងក្បែរតំបន់ការពារប្រមាណ ៤៨តំបន់ នៅក្នុងប្រទេសកម្ពុជា។ សហគមន៍តំបន់ការពារធម្មជាតិទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ និងសំណូមពររបស់អ្នកភូមិដែលមានបំណងចូលរួមគ្រប់គ្រងការពារ និងប្រើប្រាស់ធនធានធម្មជាតិនៅក្នុងសហគមន៍របស់ពួកគេនៅក្នុងនឹងនៅក្បែរតំបន់ការពារប្រកបដោយនិរន្តរភាព។ គោលដៅជាក់លាក់នៃការរៀបចំបង្កើតសហគមន៍តំបន់ ការពារធម្មជាតិគឺ ១) ដើម្បីអភិរក្សធនធានធម្មជាតិនៅជុំវិញតំបន់ការពារធម្មជាតិដើម្បីធានានូវការផ្គត់ផ្គង់ធនធានធម្មជាតិដល់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាពសម្រាប់ពេលបច្ចុប្បន្ន និងសម្រាប់កូនចៅជំនាន់ក្រោយ ២) កែលំអរធនធានធម្មជាតិដែលនៅជុំវិញតំបន់ការពារដើម្បីរក្សាលំនឹងធនធាន ធម្មជាតិ និង៣) អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការការពារ និងអភិរក្សធនធានធម្មជាតិដោយសហគមន៍មូលដ្ឋានដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរបស់ពួកគេ។ ទោះបីជាមានការកើនឡើងចំនួនតំបន់ការពារ ធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិពីមួយឆ្នាំទៅមួយឆ្នាំយ៉ាងណាក៏ដោយ មានបញ្ហាប្រឈមមួយចំនួនដែលមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការពារតម្លៃអភិរក្សជីវៈចម្រុះព្រមទាំងផ្តល់ឱកាសលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ ហើយធនធានមនុស្ស និងហិរញ្ញវត្ថុ នៅមានកម្រិត។ ការវាយតម្លៃហ័សធ្វើឡើងដោយនាយកដ្ឋានជីវភាពសហគមន៍ បានប៉ាន់ប្រមាណមានតែ១០% នៃសហគមន៍តំបន់ការពារធម្មជាតិចំនួន ១៥១សហគមន៍ ដែលគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិមានសមត្ថភាពគ្រប់គ្រងសហគមន៍ និងធនធានធម្មជាតិរបស់ពួកគេតាមរយៈការល្បាតព្រៃ ការផ្តល់សេវាអេកូ ទេសចរណ៍ និងការប្រមូលផលនឹងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព។ ទោះបីជាយ៉ាងណាក៏ដោយ សហគមន៍ តំបន់ការពារធម្មជាតិពី១០% ទៅ២០% មិនដំណើរការដោយសារតែជម្លោះដីធ្លីរវាងសហគមន៍ និងក្រុមហ៊ុនពាក់ព័ន្ធ ទៅនឹងព្រំដែនមិនច្បាស់លាស់។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

| | |
|---|---|
| កម្រិត | ពិពណ៌នា |
| មន្ត្រីរាជរដ្ឋាភិបាលថ្នាក់ជាតិ | មន្ត្រីក្រសួងបរិស្ថាន |
| អាជ្ញាធរថ្នាក់ក្រោមជាតិ | មន្ត្រីមន្ទីរបរិស្ថាន និងមន្ត្រីឧទ្យានុរក្ស |
| អាជ្ញាធរមូលដ្ឋាន | ក្រុមប្រឹក្សាឃុំសង្កាត់ |
| សហគមន៍តំបន់ការពារធម្មជាតិចំនួន៤ | គណៈកម្មការ និងសមាជិកសហគមន៍តំបន់ការពារធម្មជាតិ |
| ដៃគូរប្រឹក្សាបច្ចេកទេស | អ្នកពាក់ព័ន្ធ |

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? មាន

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

លទ្ធផលរំពឹងទុកនៃគម្រោងរយៈពេលវែងនេះរៀបរាប់ដូចខាងក្រោម៖

លទ្ធផលរំពឹងទុកទី១: ពង្រឹងចក្ខុវិស័យជាតិ និងការគាំទ្រដល់តំបន់ការពារ និងការគ្រប់គ្រងព្រៃឈើដែលមានមូលដ្ឋានតាមភូមិសាស្ត្រ

១.១ ផ្តល់ការឆ្លើយតបទៅនឹងគោលដៅជីវៈចម្រុះ និងផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ឱ្យប្រទាក់ក្រឡាគ្នាកាន់តែជោគជ័យ និងអភិបាលកិច្ចអន្តរវិស័យកាន់តែប្រសើរ

១.២ ធ្វើឱ្យប្រសើរឡើងនូវការអនុលោមជាមួយជាតិនូវគោលដៅគ្រប់គ្រងតំបន់ការពារ ជាពិសេសសម្រាប់ការអភិរក្ស សត្វព្រៃ ការប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរខុសច្បាប់ និងការថែរក្សាប្រព័ន្ធទំនាក់ទំនងតំបន់ទេសភាពនៃអេកូឡូស៊ី ព្រៃឈើ

១.៣ ធ្វើឱ្យប្រសើរឡើងនូវការគាំទ្រពីថ្នាក់ជាតិទៅលើការអភិរក្សជីវៈចម្រុះ តំបន់ការពារ និងការថែរក្សាប្រព័ន្ធទំនាក់ទំនងតំបន់ទេសភាពជាតិ ក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍន៍ជាតិ

លទ្ធផលរំពឹងទុកទី២: ដាក់បញ្ចូលការគ្រប់គ្រងតំបន់ទេសភាពដើម្បីថែរក្សាការពារព្រៃឈើ ជីវៈចម្រុះ កាបូនស្តុកនៅក្នុងតំបន់ទេសភាពវាលទំនាបភាគខាងកើត

២.១ លើកកម្ពស់សុវត្ថិភាពជីវៈចម្រុះ និងទំនាក់ទំនងប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ដោយកាត់បន្ថយការបំភាយឧស្ម័នកាបូនិចទៅក្នុងបរិយាកាស តាមរយៈការធ្វើសុខដុមរមណីយកម្មនៃការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច ទៅនឹងការ អភិរក្សព្រៃឈើ និងជីវៈចម្រុះ

២.២ លើកកម្ពស់ និងអភិវឌ្ឍសមត្ថភាពស្ថាប័ននូវការតាមដានត្រួតពិនិត្យកាបូនស្តុកព្រៃឈើនៅក្នុងតំបន់ទេសភាពវាលទំនាបភាគខាងកើត

២.៣ កៀរគរធនធានឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីដាក់បញ្ចូលការគ្រប់គ្រងតំបន់ការពារនៅក្នុងតំបន់ទេសភាពវាលទំនាបភាគខាងកើត

២.៤ បង្កើនគម្របព្រៃឈើ និងកាបូនស្តុកតាមរយៈបង្កើនការគ្រប់គ្រងធនធាននៅថ្នាក់សហគមន៍ និងសន្តិសុខស្បៀង

## ១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សុាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **២. ព្រៃឈើ** | 10 | **ទាក់ទងតិចតួច** |

## ២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងនេះបានគិតគូដល់តួនាទីរបស់បុរស និងស្ត្រី ទាំងក្រុមការងារទទួលគម្រោង និងក្រុមការងារអនុវត្តគម្រោង ជាពិសេសទាំងការងារបច្ចេកទេស និងទំនាក់ទំនង។ ជាក់ស្តែង អ្នកទទួលគម្រោងនេះ គឺជាស្ត្រីដែលមានតួនាទីជា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន។ ទន្ទឹមនឹងនេះដែរ មន្ត្រីនាយកដ្ឋានជីវភាពសហគមន៍ដែលជាស្ត្រីបានទទួលបន្ទុកផ្នែករដ្ឋបាលគ្រប់គ្រងថវិកាគម្រោងបានចុះសិក្សា និងសម្របសម្រួលការងារសហគមន៍តំបន់ការពារធម្មជាតិផងដែរ។ ហើយចំពោះកម្រិតសហគមន៍វិញមានស្ត្រី ប្រមាណពី៣០% ទៅ៤០% គឺជាគណៈកម្មការសហគមន៍។ ស្ត្រីទាំងនោះមានតួនាទីសំខាន់ក្នុងការងារទំនាក់ទំនង និងសម្របសម្រួលកិច្ចការប្រជុំការងារចិញ្ចឹមជីវិតដូចជា ការចិញ្ចឹមសត្វ ដាំដំណាំ ការប្រមូលផល អនុផលព្រៃឈើ ការរៀបចំ និងផ្តល់សេវាទេសចរណ៍ធម្មជាតិ ព្រមទាំងចុះល្បាតព្រៃជាមួយបុរសៗផងដែរ។

២២. សមត្ថភាពអនុវត្តគម្រោង (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

នាយកដ្ឋានជីវភាពសហគមន៍មានតួនាទីសំខាន់ៗចំនួនបួនដូចជា៖
១)ការងារសម្របសម្រួលរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ២)ការងារលើកកម្ពស់ជីវភាពសហគមន៍តាមរយៈការចិញ្ចឹមសត្វ ដាំបន្លែ ផ្គត់ផ្គង់ប្រព័ន្ធទឹក និងតទុយយោ
២៣. ៣)ការលើកកម្ពស់សមត្ថភាពដល់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រង ធនធានធម្មជាតិ ៤)ការផ្សព្វផ្សាយអំពីគោលនយោបាយ ផែនការ ច្បាប់ និងបច្ចេកទេស ដើម្បីពង្រឹងការគ្រប់គ្រងធនធានធម្មជាតិដល់ គណៈកម្មការសមាជិកសហគមន៍ ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធ ការងារស្នូលទាំងបួនខាងលើនេះ ជួយឱ្យគម្រោងនេះនឹងទទួលបានជោគជ័យ និងមាននិរន្តរភាព

ជាការពិតណាស់ គម្រោងនេះមានការយឺតយ៉ាវក្នុងការអនុវត្ត ដោយសារតែនីតិវិធី និងបែបបទ ជាពិសេស បែបបទក្នុងការទទួលបានកញ្ចប់ថវិកាត្រូវការពេលយូរ។ ដូចនេះ ក្រុមការងារពុំអាចចាប់ផ្តើមគម្រោងតាមកាលកំណត់ដូចដែលបានលើកឡើងបានទេ។

២៤. អាទិភាពរបស់គម្រោង (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

6

២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2019 | | 2020 | 2021 | 2022 | 2023 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2021-2023 | ចរន្ត |
| ចំណាយប្រតិបត្តិ | 10.9 | 6.3 | 10.9 | 9.4 | 0.0 | 0.0 | 9.4 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 6.0 | 6.0 | 6.0 | 6.0 | 0.0 | 0.0 | 6.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 1.3 | 0.0 | 1.3 | 0.1 | 0.0 | 0.0 | 0.1 | 0.0 |
| ផ្សេងៗ | 3.6 | 0.3 | 3.6 | 3.3 | 0.0 | 0.0 | 3.3 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំណាយមូលធន** | 35.1 | 24.8 | 35.5 | 27.0 | 0.0 | 0.0 | 27.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 3.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 7.8 | 13.2 | 2.1 | 2.9 | 0.0 | 0.0 | 2.9 | 0.0 |
| ផ្សេងៗ | 26.7 | 8.6 | 33.4 | 24.1 | 0.0 | 0.0 | 24.1 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 46.0 | 31.1 | 46.4 | 36.4 | 0.0 | 0.0 | 36.4 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2019 | | 2020 | 2021 | 2022 | 2023 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2021-2023 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 46.0 | 31.1 | 46.4 | 36.4 | 0.0 | 0.0 | 36.4 | |
| | | | | | | | | |
| Global Fund | 46.0 | 31.1 | 46.4 | 36.4 | 0.0 | 0.0 | 36.4 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 46.0 | 31.1 | 46.4 | 36.4 | 0.0 | 0.0 | 36.4 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: